# កម្ពុជសុរិយា

## ប្រវត្តិព្រះឥន្ទ និងសង្គ្រាមអសុរ

លោក ឆល ជិត

និពន្ធជាពាក្យកាព្យតាមសេចក្ដីក្នុងគម្ពីរសារត្ថទីបនី

ភ្នំពេញ
ការផ្សាយពីពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥០៨
គ. ស. ១៩៦២

# ប្រវត្តិព្រះឥន្ទ នឹង សង្គ្រាមអសុរ

លោក ជល-ឌិន នៅក្នុងសាសនបណ្ឌិត្យ

និពន្ធជាពាក្យកាព្យតាមសេចក្ដីក្នុងគម្ពីរសោតត្ថទីបនី

## វិនយដីកា សមន្តប្បាសាទិកាវណ្ណនា

> ប្រវត្តិព្រះឥន្ទ ទេវរាជ
> ដែលភាគអំណាច នៅសួគ៌
> នឹងអសុរយុទ្ធ ដោយយោធា
> ចុះមិត្រភាពគ្នា កំណត់ដឹង

រឿងនេះមានខែងថ្លៃថ្លាអត្ថ

គម្ពីរសោតត្ថ បទដីកា ជារឿងពិរោះចាប់ចិត្ត
ដូចជាតម្រាយុទ្ធសាស្ត្រ ។ តាមរឿងដំណាលពីព្រេងព្រឹទ្ធ
អតីតកន្លងយូរលង់ណាស់ ជារឿងនិពន្ធដ៏ចាស់

និទានជាក់ច្បាស់និយាយថា ៖

កាលដំណាលពីដើមកប្ប មានចៅមាណពម្នាក់សោភា
គេហៅ មឃៈ រល់ ១ គ្នា នៅនាស្រុកឈ្មោះអចលគ្រាម ។
គាត់មានភរិយាគ្នាបួននាក់ ទឹងមានមិត្រភក្ដិមិនជាក់ខាម
ដែលស្មោះស្មើខ្លួនចំនួនសាម- សិបពីរនាក់តាមគម្ពីរថ្លែង ។

គាត់ដើបបួនជនបទ(១)　　ដែលស្ដេចកំណត់ប្រទានវែង
ចែកឲ្យជាសួយមួយកន្លែង　　ដើម្បីចាត់ចែងការស្រុកប្រជា ។
មិត្រគាត់ទាំងសាមសិបពីរប្រាណ　　ក៏បានចំណែកគ្រប់គ្នា
គឺជាស្រុកនោះទាំងអស់គ្នា　　មូលមិត្រចិត្តាឥតរង្គ ។
ឯលោក មឃៈ ជាប្រធាន　　នាំមិត្រគ្រប់ប្រាណមកនៅជុំ
បង្កើតបានជាសមាគម　　ឧបត្ថម្ភកសាងប្រយោជន៍ជាតិ ។
ចំណាយកម្លាំងទាំងធនធាន　　ជីកនាំសន្តានឲ្យខ្មីឃ្មាត
សាងសាលារៀនយ៉ាងល្អស្អាត　　សង្ហាតសាងផ្លូវទៅពេញស្រុក ។
សាងស្រះជាសហានដែលគ្មានទឹក　　នាំជីកដីកព្រែកចែកច្រើនមុខ
សាងរោងសំណាក់ត្រជាក់សុខ　　សាងស្ពានក្នុងស្រុកទុកកស្រួង ។
នាំគ្នាប្រព្រឹត្តយ៉ាងម៉ត់ចត់　　នូវ វត្តបទ(២) ប្រាំពីរផង
ធ្វើបុណ្យសុន្ទរទានពុំមានហ្មង　　កខ្វង់យូរយារតាចព្រួយ ។
លុះដល់កំណត់ផុតជន្មា　　ក្អកទាំងអស់គ្នាវេលាក្ស័យ
ក៏បានកើតក្នុងសួគ៌ាល័យ　　អាស្រ័យបុណ្យទានជាយានទៅ ។
គឺបុណ្យគុណកើតពីការសាង　　ប្រយោជន៍គ្រប់យ៉ាងឥតហ្មងសៅ
ជួយជនទាំងសាមសិបបីទៅ　　ឲ្យកើតឋិតនៅផ្លូវសុខា ។

---

១ គ្រប់គ្រងស្រុកចុងកាត់មាត់ញកបែបដូចជាស្ដេចត្រាញ់ ។ ២ វត្តបទប្រាំពីរប្រការមានក្នុងគម្ពីរធម្មបទដ្ឋកថាត្រង់សក្កវត្ថុ ភាគ ២ ។

កាលនោះព្រះបាទៈវេបចិត្តិ ស្ដេចបិតជាម្ចាស់ឋានសួគា
លុះឃើញទេវបុត្រទាំងអស់គ្នា កើតនាវិមានឋានព្រះឥន្ទ ៗ
ស្ដេចមានព្រះទ័យថ្លៃស្មោះសរ អបអរពេកពាក់ស្ម័គ្រស្មោះក្រន់
ចាត់ចែងទទួលស្រួលអស់ឥន្ទ ដោយចន់ជាមិត្រស្និទ្ធមេត្រី ៗ
បែងចែកសម្បត្តិក្នុងទេវលោក ព្រោះយោគយល់ចិត្តមិត្រកើតថ្មី
ដែលមកជុំទាំងសាមសិបបី ចក្រីរៀបចំសមឥតខ្ចោះ ៗ
ប្រមូលអស់ថែបទេពធីតា ដ៏មានកាយាថ្លាឥតមោះ
ទ្រូងតើងឡើងពេញចេញផងពោះ គួរដោះក្បិតក្បូរដូចគេវេច ៗ
ដួងភ្នែកផ្អែកក្អឹតទ្វិតទាំង ពាក់ក្យាំងពាំងក្បាលរន្ទួលរលេច
ខ្ទមាសពាសដាំអង្កាំពេជ្រ កម្ទេចស្មើរង្សីថ្លា ៗ
ព្រះភ័ក្ត្រស្រស់ស្រើបរលើបស្រិល រអិលព្រិលព្រួចក្លួចចិន្តា
សម្ផស្សសោភ័ណទន់សោភា កេសាឥតសៅខ្មៅយ៉ាងស្រស់ ៗ
ល្អអើយល្អណាស់ល្អគ្រប់គ្នា ច្រើនឥតគណនាកប់មិនអស់
ពន្លះចាមពេមពេញជាកិត្តិយស ផ្សាយសេពដោរត្នួរបេត្តី ៗ
បញ្ចេញឈ្មោញសើចសំណើចស្រួល ទទួលពេញចិត្តមិត្រកើតថ្មី ៗ
ស្រាយស្រស់ផ្កោះផ្តងសងសំដី សំដែងមេត្រីស្រីឆោមឆាយ ៗ
ពាសពេញរឿណារន្ធតង់ពើក លាតលើកដៃដើងឡើងពង្រាយ
រាំបែរបេវ៉មិតពត់កាយ មិត្រថ្មីទាំងឡាយសប្បាយលន់ ៗ

នាងនាដកិត្តិ(១)ស្រីអប្សរ    លើកករចោកក្បាច់កាច់ទន់អន្ទ

កៀកកាយ លាយកាមតាមទម្រង់    ជន្ទង់ពង់ពើងឡើងល្ហាសល្ហន់ ។

ជាពួកជាក្រុមជុំអធិក    ភ្ញុកភ្ញឹកតឹកកង់គួរគយគន់

ទេពតាកើតថ្មីព្រះទ័យទន់    សប្បាយតេកពន់ក់ន្តអាត្មា ។

ស្ងូរសព្ទសំឡេងបទភ្លេងទិព្វ    រូបរឹបដូចចិត្តមិត្រទេវតា

ពីពេះអើយពីពេះហួសឧបមា    គួរព្រឺរណ្តាថ្វាហឫទ័យ ។

នៅក្នុងប្រាសាទស្អាតប្រសើរ    ខ្ពស់ទើរលើភពនភាល័យ

ក្បូរក្បាច់ចេនាវាសនាថ្ងៃ    ល្អហួសវិស័យនៃមនុស្សឋាន ។

ស្ងួនសឹងតែមាសពាសដោយពេជ្រ    រំលេចវៃទូរ្យសូរ្យកាន្ត

មណីរត្នពុំដូចគ្រប់ឋាន    ប្រមាណសន្ធឹងធំល្វឹងល្វើយ ។

ទេពតាកប់ច្រើនម៉ឺនចូលចេញ    នៅតែមិនពេញប្រាសាទឡើយ

អាកាសត្រជាក់ខ្យល់រំភើយ    រហើយស្រួលប្រាណក្សាន្តពន់ពេក ។

ទេវបុត្រតូចធំសមតាមថ្នាក់    យសសក្តិកប់ម៉ឺនច្រើនអនេក

ខ្លះក្រោកឡើងកំខ្លះទំស្រែក    សរៃម្រែកចម្រៀងច្រៀងសប្បាយ ។

ឯស្តេចទេពតាបក្កាន់    លើកផ្កាចន្ទុមទិព្វពណ្ណរាយ

នាំអស់បរិវារផងទាំងឡាយ    ចូលថ្វាយបំពោះទេពតាថ្មី ។

ដែលមាននាមថា សញ្ញា:    ឲ្យគ្រងការៈអធិបតី

---

១ ស្រីរបាំ ។

សោយយកផលសម្បត្តិទិព្វសួស្តី　កាន់កាប់ផែនដីពាក់កណ្ដាល ។
រួចស្រេចស្ដេចទ្រង់ឲ្យតាក់តែង　គក់តែងស្រាជ័យថ្លៃក្រៃកាល
ឲ្យអស់ទេវតាតាំងចក្រវាឡ　ក្រអាលផឹកគ្រប់បែបកំសាន្ត ។
ជាសាធុការថ្លាប្រពៃ　ប្រសិទ្ធះជាគជ័យថ្លៃចំណាន
ដល់មិត្រចំណូលសាមប៉ីប្រាណ　ឲ្យបានមង្គលសុខះថេរប៉ិត ។
ឯពួក សត្តា៖ អ្នកកើតថ្មី　តាំងសាមសិបប៉ីមិនពេញចិត្ត
ព្រោះឃើញសម្បត្តិសម្បើមពិត　ក្តួចចិត្តចង់បានរាជ្យតាំងអស់ ។
ក៏ឲ្យសញ្ញាអាថ៌កំបាំង　ប្រុងប្រៀបប្រឆាំងដណ្ដើមយស
ធ្វើកល។បាយយកតាំងអស់　ប្រាថ្នាធំខ្ពស់តាំងសាកល ។
ឯពួកទេវតាជាម្ចាស់រាជ្យ　ប្រសេចប្រសាចដើរចល់
តាក់ស្រាហាផឹកឥតទឹកខ្វល់　ច្របល់ជ្រួលជ្រើមសម្បើមក្រៃ ។
ខ្លះលើកបើកឆ្នុកដែលចុកដប　រៀបរបតាក់ក្នុងកែវចរណៃ
ខ្លះក្រេបបែបធ្ងន់ទន់ដើងដៃ　ខ្លះលៃបង្អកប្រកមិត្រភក្ដិ ។
ខ្លះជ្រួសហួសពេកដេកសន្ធឹង　នេត្រស្ញឹងរឹងស្លុកមុខខ្មៅឃ្មាក់
ខ្លះក្រោកដោកដាក់អស់នាងអ្នក　បញ្ចូញសង្វាក់ក៏កំសាន្ត ។
ខ្លះទៀតប្រមឹកផឹកឥតក្រែង　ដួលដេកចំខែងលែងដឹងប្រាណ
រដោករដុលជ្រុលប្រមាណ　ដេរដាសពាសពានគ្មានសេសសល់ ។
ឯពួកស្រីស្រស់ទេពអប្សរ　ក៏ផឹកកែវច្រួលច្របល់

កៀកកៃស្នេហ៍ស្និទ្ធចិត្តវិលវល់　　អស់កល់កេរ្តាសផ្ដេសផ្ដាសអត្ថ ៗ
ប្រឡូកប្លុកប្រឡំបល់　　គ្រប់កាយខ្វាយខ្វល់តាមចំណង់
ប្រើនប្រឹតគិតតែកែទម្រង់　　កៀកអង្គតង់អែបខែបតូតាប់ ៗ
ពួកក្មេងលេងខ្ញុំវញៀវពិកគព　　គ្មានឈប់សម្រាកផ្អាកសួរស័ព្ទ
ក្មេងអើយក្មេងក្បាន្តគ្មានទឹកស្ងាប់　　ទឹកបញ្ជាប់ក្រមក្រឹត្យគួរគិតក្រែង ៗ
ឯពួក សញ្ញាៈ អ្នកកើតថ្មី　　តាំងសាមសិបបីក៏សំដែង
អាការដូចជាប្រើនផឹកលេង　　ស្រវឹងវង្វេងគ្រប់ ៗ គ្នា ៗ
លុះឃើញទេវតាដែលនៅមុន　　ផឹកស៊ុនទន់ខ្លួនដួនតែស្រា
ដួលជាសពាសទហ៊ាននានា　　លែងដឹងកាយាក្វរស្មារតី ៗ
ទ្រេតទ្រោតដួលចុះខុសទំនង　　ដេកគង់តាក់តាំលែងដឹងអ្វី
លេចមុខខុកក្រោយមិនគប្បី　　ស្រីស្រីក៏គ្មានប្រាណអៀនខ្មាសៗ
ដេកផ្កាប់ដេកផ្ងារហាមុខក្រោយ　　ខ្លះដួលបណ្តោយដេកបញ្ច្រាស
ខ្លះដេកយកដៃលៃខ្លួបថ្ពាស　　ខ្លះប្រាសជើងគង់វិលក្បាល ៗ
ខ្លះនៅលើគុសំកុកជ្ឈង　　ទុបស្រីព្រលឹងប្រឹងក្រអាល
ទោរទន់សញ្ញាៈជាយក្តីពាល　　ទុនក្បាលជ្រុលជ្រប់ផ្ទប់មុខគ្នា ៗ
សញ្ញាៈឃើញទោះអស់ចារម្ភ　　បង្ខំមិត្រក្រាមតាមសញ្ញា
ឲ្យចូលចំបាប់ចាប់ទេវតា　　ដែលមានបុណ្យានុភាពធំ ។
ដឹងពួកបក្សពំផ្សាប្រេនកាក់　　មានបញ្ញាក់ស័ក្តិខ្ពស់យសឧត្តម

មិត្រថ្មីសាមីបន្ទាន់ប្រាថ្ក
ស្ទុះចំទំហូលទ្ធលជើងដៃ ។
កន្ត្រាក់ចាប់ជើងពួកប្រមឹក
ដែលផឹកស្រាងើបហួសវិស័យ
ត្រីត្រេកតក្អាក់អស់ដៃ
ពីសួគាល័យយ៉ាងកំណាច ។
ត្រូវនេះពាលក្ដិងអន្ទង់ធំ
ធ្លាក់ទៅបាតភ្នំសិនេរុរាជ(១)
សន្ធាះខ្ទបឯងឥតក្រែងខ្លាច
អំណាចតេជះព្រះបេស្តា ។
ស្ទុះចូលឆ្លូលក្បួរបួរជើងមិត្រ
នាម វេបចិត្តិ មហាកដាំ
ត្រកក់យ៉ាងខ្លាំងកម្លាំងក្លា
ខ្លួនតាគហត្ថាធ្លាក់ចុះរ៉ង ។
ទេពទិកដោះច្រើនកើនម៉ឺនលាន
ខ្លាត់ចាកវិមានគ្មានដំណឹង
ជ្រុះទៅបាតភ្នំជុំស្លុកស្តឹង
ពាល់តែស្លាក់ឈឹងពីសួគ៌ា ។
នៅសល់ទេវតាណាស្មោះត្រង់
ព្រមអង្គផ្ទង់កាយថ្វាយវន្ទា
សូត្រចូលមូលមិត្រចិត្តរួមគ្នា
ទើបរួចអាត្មាពីគ្រោះថ្នាក់ ។
ឯពួកស្រវឹងសឹងដេកផ្ទុយ
ជ្រុះចុះរប៉ុយដូចក្អៀងធ្លាក់
ទៅតរលើគ្នាជាច្រើននាក់
ឥតក្បាក់កាយាផ្កាប់ផ្ងារប្រាណ ។
ដោយកត្វកាតផលកុសលបុណ្យ
ពួកទេវតាមុនតាំងប៉ុន្មាន
គ្រាន់តែបែរជ្រុះចុះដល់ឋាន
វិមានបាតភ្នំផ្តុំគ្នាក្លាយ ។
កើតនៅជាកតាដែនប្រឹថពី
ជាទីរុងរឿងក្រុងសប្បាយ
មានជ្រុងកំពែងវែងកន្ទ្លាយ
ចម្ងាយមួយម៉ឺនកើនយោជន៍យល់ ។

---

• ភ្នំព្រះសុមេរុ ។

ផុសប្រាង្គស្អាងស្អាតប្រាសាទច្រើន ដាំត្បូងរូងក្បាច់បុប្ផាផល
មានស្រ្តីអប្សរល្អខេមិល មៀងយល់ដូចជាសួគ៌ាល័យ ។
មានដើមប្រខៀង(១)ធៀងជាក់ចិត្ត សស្រាប់ផុះឡើងភ្លើងពេកក្រៃ
មណីរត្នពន្លឺភ្លឺដូចថ្ងៃ វិស័យសួគ៌ឋានគ្មានប្លែកឡើយ ។
លុះពួកទេពតាភ្ញាក់ប្រាណ មៀងមើលវិមានឋាននោះហើយ
ឃើញអស់ពួកមិត្រដិតបង្កើយ ស្មានតែហ្នឹងហើយឋានប្រក្រតី ។
គិតតែតែក្បាច់បង្អាច់កាយ លោកកំសប្បាយគ្មានគិតអ្វី
ឥតទុក្ខសុខក្សេមដ៏ប្រែមប្រិយ សួស្តីឥតខានតន់ពេកក្ដូវ ។
នេះគឺដោយផលពីអតីត វិចិត្រកើតឡើងដោយរដូវ
មានកម្មតាំជួយស្ទួយតម្រូវ ទីនផ្លូវបច្ច័យលៃសានឲ្យ ។
ឯពួកសត្តាៈអ្នកប្រយុទ្ធ ជាទេវបុត្រកើតជាន់ក្រោយ
វាយប្តូរស្វីប្រាណបានពង្សសោយ គឺដោយតេជៈបុណ្យបារមី ។
ពួកទេពតាតាស់ផ្លាស់ឋានៈ ព្រោះតែសត្តាៈអ្នកកើតថ្មី
ធ្វើកលទេបាយយកផែនដី មានជោគសួស្តីជ័យសិទ្ធសេរ ។
លុះចាប់មិត្រខ្ជុំផ្ទុំបោលក្ន អន្ទង់បាតភ្នំព្រះសុមេរុ
អស់ស្រេចទេវាស្តេចនាំគ្នាបែរ រៀបគ្នាពង្រីកអាណាចក្រ ។
បរពលយោធាជាអធិក គគ្រឹកគគ្គឹកឡោះហោះប្រពាក់
ប្រទើសលើសកើនច្រើនអនេក្ខ ជាបក្សព្រះឥន្ទ្រពិនបក្រាល ។

១ ដើមចិត្របាលិ ។

ចិត្តដូចអគ្គីឫទ្ធិក្លា
គណនាដំរើនកើនចំនួន ។

គឺឲ្យជាអ្នកត្រូវតាំងចាត់
នៅចាំសង្កាត់ផ្លូវទ័ពខ្លួន

បើបច្ចាមិត្រចិត្តមាំមួន
ចូលដល់ផ្ទាល់ខ្លួនផ្ទួនកម្លាំង ។

ត្រូវបក្សយក្សយន់ពង្សក្លាហាន
ប្រុងប្រាណប្រយុទ្ធឈ្លុតប្រទាំង

រៀបចំក្រុមទ័ពចូលទប់ច្បាំង
បន្ថយកម្លាំងកងរឿណរង្គ ។

បន្ទាប់ពីពួកយក្សមកទៀត
ផុតទ័ពស្មៀតជ្រៀតផ្លូវត្រង់

ចាត់តាំងមហាពជទាំងបួនអង្គ
ឲ្យរង់គង់ឃ្មាំប្រចាំការ ។

និត្យនៅផ្លូវដើរឡើងទៅចំ
លើភ្នំសិនេរុបរិករ[១]

មានកងក្លាហានប្រចាំការ
អធិកឡារពាន់ពេកក្រៃ ។

កងទ័ពមហាពជអង់អាចណាស់
សុទ្ធសឹងដើងចាស់តបះតេជដៃ

មួយពួកមួយពួកមានទង់ជ័យ
ដងខ្ពស់លលៃជាសញ្ញា ។

លុះតាំងប៉ុងចាត់សង្កាត់សឹក
ផ្លូវគោក ផ្លូវទឹក - អាកាសា

ស្រេចហើយសញ្ញាះឫទ្ធិក្លា
ទីងពួកទេវតាជាមិត្រភក្តិ ។

នាំគ្នាចូលក្នុងកំងប្រាសាទ
រកអាច្យដំឡើងថ្កើនបុណ្យស័ក្តិ

មូលម័តចាត់ការពារពិភក្តិ
តាំងសាមប័នាក់តាមថ្នាក់ជាន់ ។

ពេលនោះប្រាសាទស្អាតត្រសុស
ប្រជ្រៀតគ្នាផុសច្រើនហ៊ឹនពាន់

ខ្ទះទាបកបទាលខ្ទះច្រើនជាន់
ចេញកប់ម៉ឺនពាន់ហួសគណនា ។

---

១ ភ្នំដែលនៅជុំវិញភ្នំព្រះសុមេរុ មានភ្នំឈ្មោះយុគន្ធរជាដើម ។

ទេវពិភពលុបឈ្មោះចាស់  នាមផ្លាស់ថាត្រៃត្រឹង្សត្តិ
ឬហៅពិភពតាវត្តិំសា  ដោយនាមទេវតាសាមបីប្រាណ ។
តាំងនៅលើថ្ងៃនៃមហាភ្នំ  ទំហំធំខ្ពស់ហួសប្រមាណ
គឺភ្នំសិនេរុរាជហាន[១]  វិមានគុះគុំជុំច្រើនក្រៃ ។
ជាទេពនគរល្អត្រកាល  ធំភលដាលឆ្ងាយដាច់អាល័យ
មានទ្វារមួយពាន់កំពឹកលំថ្វៃ  វិស័យកំពែងវែងមាំមួន ។
គឺកំពែងក្រុងជ្រុងមួយ ៗ  មាំផុតរញ្ជួយព្រួយរត់ពួន
ប្រវែងមួយម៉ឺនយោជន៍តាំងបួន  ចំនួនដប់កោដិយោជន៍ក្រឡា ។
ខាងក្នុងនគរល្អត្រចះ  មានស្រះបោក្ខរណីដ៏ថ្លា
សួនច្បារផ្កាដុះដុសត្រៀបត្រា  បុប្ផាជម្រុះរីកស្គុសស្គាយ ។
មានរុក្ខជាតិមានធំខ្ពស់  សន្ទឹកខៀវស្រស់ដុះពង្រាយ
ជាផ្លូវជាក្រុមសមឆើតឆាយ  គួរឲ្យសប្បាយដើរកំសាន្ត ។
នៅមជ្ឈមណ្ឌលយល់ត្រកាល  ជាទីកណ្ដាលបូរីហាន
ប្រាសាទមួយធំសមប្រមាណ  សម្រាប់ក្សត្រក្សាន្តព្រះទ្រង់យស ។
ឈ្មោះថាប្រាសាទវេជយ័ន្ត  ប្រកបថ្នាក់ជាន់ពេជម៉ឺនអស់
ជហ្វាប្រសព្វគ្រប់ទិសទស  ឆើតឆាយសម្រស់ស្រស់ញញឹម ។
កំពូលកម្ពស់ខ្ពស់ត្រដោច  ប្រាំពីររយយោជន៍យល់សន្ធឹម
ក្បូរក្បាច់ចេនាថ្មុំប៉ប្រិម  រកគូប្រៀបផ្ទឹមពុំបាន ។

---
១ ភ្នំព្រះសុមេរុ ។

សុទ្ធសឹងដោយមាសនុការសរផុត　　រស្មីចាំងភ្លឺគ្រប់ទីឋាន
ក្បឿងពេជ្រនៃពិទូរ្យបុស្សរាគន្ត　　ដ៏មានរិទ្ធិភ្លឺដូចថ្ងៃ ៗ
ខាងលើប្រាសាទស្អាតគ្រប់ជាន់　　មានដោតជ្រងទង់ខ្ពស់លំលៃ
សុទ្ធសឹងមាសពេជ្រល្អពេកក្រៃ　　វិស័យមនុស្សលោកយោគមិនយល់ ៗ
មានកដរថមួយឈ្មោះវេជយន្ត　　ទឹមសេះពីរពាន់មហាពល(១)
ក្បូរក្បាច់ទេមាថ្វាទិមិល　　ជាផលផ្តល់ផ្តើងរុងរឿងឫទ្ធិ ៗ
រថនេះជាយានថ្កានប្រសើរ　　ហោះហើរដើរបានគ្រប់ឋានបិត
សម្រាប់សក្កៈអ្នកមានឫទ្ធិ　　ឆ្ងាយជិតស្ដេចគង់ថ្កានយាត្រា ៗ
មានដំរីមួយសមសោភ័ណ　　ឈ្មោះឰរាវ័ណសមសោភា
ជាទេពនិម្មិត(២)ឋិតសួគ៌ា　　សម្រាប់កជាព្រះទ្រង់យស ៗ
មានរោងប្រជុំក្រុមទេវតា　　ឈ្មោះសុធម្មាទូលាយខ្ពស់
មានច្បារផ្កាក្លិនគន្ធរស　　យ៉ាងស្រស់ឈ្មោះចិត្តលតាវ័ន ៗ
មានស្រះបទុមជុំបុប្ផា　　ឈ្មោះសុនន្ទាជាតំបន់
ទឹកថ្លាត្រជាក់ស្រួលពេកពន់　　គួរគន់ចុះមុជកែកំសាន្ត ៗ
ទីក្រុងតាំងមូលពោលដោយខ្លី　　រស្មីពន្លឺភ្លឺសព្វឋាន
ចតុរង្គរុងរឿងល្អផ្តើងថ្កាន　　ទេវតាប៉ុន្មានក្សេមក្សាន្តសុខ ៗ

---

១ មានកម្លាំងច្រើន ។ ២ នៃលទេវបុត្រមួយអង្គនិម្មិតខ្លួនជាដំរីសម្រាប់ស្ដេចគង់កំសាន្ត ។

ឯមិត្រទាំងសាមសិបបីនាក់ ស្មោះស្ម័គ្រគ្រប់ប្រាណបានដាក់ទុក
លើកឥន្ទសក្កៈជាប្រមុខ គ្រប់គ្រងភូមិស្រុកគន់សួគ៌ា ។
សក្កៈពេលនោះឈ្មោះវិចិត្រ ជានាមនិមិត្តច្រើនមហិមា
គឺនាមដែលពួកមនុស្សទេវតា នាំគ្នាហៅថា ព្រះបុរិន្ទទ(១) ។
ហៅ តិទិវាធិភូ, បុរិន្ទទ ទេវិន្ទ, បាកសាសនោ
ទេវកុញ្ជរៈ, វាសវោ សុរនាថោ, ជម្ភារី ។
វជិរហត្ថ, អមរិន្ទោ គន្ធព្វរាជា, សុជម្បតី
អសុរភិក្ខូ, ព្រះកោសិយ ភូតបតី, សុរាធិបៈ ។
វជិរវុធ, មឃវា ទេវរាជា, សហស្សក្ខៈ
សុរិន្ទ, អសុរសាសនៈ ទសសតលោចនោ ។
វត្រភូ, ទេវានមិន្ទ ឥន្ទ្រៈ, មហិន្ទ, សហស្សនេត្ត
សក្កៈ, តិសម្បមុខោ បជាធិបោ(២) ដូច្នេះក៏មាន ។
សោយសុខសម្បត្តិសម្បើមបុណ្យ សម្បូណ៌ដោយគុណកបកល្យាណ
ពួកស្ត្រីអប្សរទេវប្រាណ ពេញឋានវិការីរដេរដាស ។
ទាំងពួកទេវបុត្រច្បុតកើត យានយកកំណើតទេវភាស
កើតកើនច្រើនឡើងដេរដាស ពេញពាសគគុញគន់សួគ៌ា ។
គឺដោយសារគុណនៃសក្កៈ បានឡើងឋានៈទេវរាជា

---

១ បុរសជាអធិបតី។ ២ ទាំងពីរ តិទិវាធិភូ និង បជាធិបោ :ន: ជាឈ្មោះរបស់សក្កៈទាំងអស់។

មានបុណ្យអស្ចារ្យហួសគណនា ធំលើសទេវតាផងឯទៀត ។
ថ្លៃថ្លាទេពតាដែលជាម្ចាស់ កាលផ្លាស់ឋានៈដោយធ្លាក់ស្បៀត
គិតតែកែខ្លួនផ្ទួនស្រាទៀត ប្រឹងឆ្មៀតជ្រៀតជ្រែងលេងសប្បាយ ។
អត់ខ្លួនអត់គិតពិចិត្យឋាន ពឹងតែកំសាន្តគ្មានក្រហាយ
ស្មានថាខ្លួនជាទេពនិកាយ នៅសួគ៌ាឆាយអត់ខ្វាយខ្វាត់ ។
មានអាយុវែងសម្បុរស្រស់ មានឥស្សរិយយសខ្ពស់ពេកក្កាត់
សម្បូណ៌សម្បើមឆ្នើមសម្បត្តិ វិស័យបុណ្យពាត់ដូចសួគ៌ា ។
គឹកង់ទេវលោកយោគសុខសាន្ត អត់ទុស្ថានបែបយ៉ាងណា
ឯអសុរកពគ្រប់ទិព ក៏សែនសុខាដូច្នោះឯង ។
ហេតុនេះទើបពួកគេគ្រប់ប្រាណ មិនបានដឹងខ្លួនផ្ទួនវេង
ប្រឹងតែស្មានថាទីនោះឯង ជាទីកន្លែងសួគ៌ាល័យ ។
លុះដល់វដ្តត្រូវធាត់ជៀង ពេលដើមប្រទៀងទិព្វត្រូវឈ
បញ្ចេញបុប្ផាជាវិស័យ រីកស្រស់បំព្រៃប្រល្អផើតផាយ ។
ស្រាប់តែពួកគេវេទនិត រីគិតពិចិត្យដោយភ្ញាក់កាយ
ថាដើ ! យើងពឹងតែសប្បាយ គ្មានក្តៅក្រហាយគិតអើពើ ។
ពួកយើងមិនមែនជាទេពតា នៅឋានសួគ៌ាលោកទេតើ
អាដែងគ្នាយើងពិតជាក្លើ ឲ្យសក្កៈធ្វើកលបញ្ឆោត ។

គិតតែពីផឹកទឹកស្រវឹង មួយដបហើយច្រើនថែមមួយប៉ោត
មួយប៉ាន់កាន់ដើរលើកោដ សក្កៈបញ្ចោតលោតធ្លាក់ទឹក ។
ពួកឯងឃើញទេដើមប្រទៀង ដុះផ្សៀងរៀងផ្កាផ្ញុំសន្ទឹក
ឯណាដើមបារិច្ឆត្តកព្រឹក្ស(១) រីករើកហើយយើងគ្មានជីងកាយ ។
ឋានសួគ៌មានដើមបារិច្ឆត្ត ជាទេពសម្បត្តិស្រស់ឆើតឆាយ
ជាទីញុំាំងទេពតាតាំងឡាយ ឲ្យក្សាន្តសប្បាយកាយសួស្តី ។
ឥឡូវនៅមានឯប្រទៀង គ្មានសូរសំនៀងសៀងសព្វអ្វី
ឃើ ! ពួកសក្កៈអន្តរិយ អប្រិយក្រៃក្រលមើលឆាយធំ ។
ឡើយើងឲ្យបង់លង់កាយា លះភាពទេពតាសក្តិឧត្តម
កើតជាអសុរក្រុលបាតក្ខ ទុក្ខធំនេះរកប្រៀបពុំបាន ។
ពីដើមគេហៅយើងសុរា ប្រែជាទេពតាក្នុងសួគ៌ឋាន
ឥឡូវបង់ប្រាជ្ញាដាចថ្នាក់ប្រាណ មកបានឋានថៃរប្រែនាមា ។
ទៅជាអសុរក្រលបពិត ព្រោះតែការក្បត់ពួកទេពតា
ដែលយើងសប្បុរសស្មោះចិត្តា តាំងលើកសីមាពាក់កណ្តាល ។

---

១ បារិច្ឆត្តកព្រឹក្ស គឺដើមមន្ទាបុស្បដុះនៅឋានសួគ៌ ។

(នៅមានត)

# ប្រវត្តិព្រះឥន្ទ និង សង្គ្រាមអសុរ

លោក ជល-ឌិត នៅក្នុងសាសនបណ្ឌិត្យ

និពន្ធជាពាក្យកាព្យតាមសេចក្ដីក្នុងគម្ពីរសោត្តទីបនី

## វិនយដីកា សមន្តប្បាសាទិកាវណ្ណនា

(តមក)

ប្រវត្តិព្រះឥន្ទ ទេវរាជ
ដែលភាគអំណាច នៅសួគ៌ា
នឹងអសុរយុទ្ធ ដោយយោធា
ពួកមិត្រភល់គ្នា កំណត់ដឹង

ឲ្យគេសេពសោយដោយអាណិត　　គេមិនពេញចិត្តត្រេកត្រអាល
បែរជាកធ្វើអំពើពាល　　បណ្ដាលកម្រោលតោលយើងអស់ៗ
មករឹយ ! ពួកយើងកុំញញើនៅ　　បបួលគ្នាទៅរកកិត្តិយស
សម្លាប់កាប់គ្នាឲ្យអស់　　កុំឲ្យរស់ខ្ពស់សាកល ៗ
ពេលនោះព្រះបាទវេបចិត្តិ　　បង្ខិតមិត្រក្រុមបង្គំពល
នោះគងខ្ចីស្គរខ្ទរមល្ហល　　ពលរៀបទ័ពជាប់សន្ទាក់ ៗ
ទឹកឃើញរឿងដើមដង្ហើមធំ　　ស្ទើរយំអួលឯកបែកប្រមាត់
ប្រជុំយោធាជាសន្ទាក់　　សម្បើមពេកក្ដាត់ញ័រប្រឹថពី ៗ

ខ្លះលើកដំបងគងលើស្មា ខ្លះកងសង្ហាហោះវក់វី
ខ្លះកងសង្គិះដិះសេះញី ខ្លះលីប៉ូវចៅមើលទៅនាយ ៗ
ខ្លះលើកក្រវិរកាន់ដាវផ្គាក់ ខ្លះទាញកន្ត្រាក់ធ្នូមកស្ពាយ
ខ្លះខ្ជូចល្មួចមើលព្រើលនាយអាយ បែរកាយនេបនិត្យដិតស្រើស្រើ ៗ
ខ្លះដកព្រួញចេញពីបំពង់ ផ្គងធ្នូតម្រង់ឆ្ពង់ស្មារតី
សាកមើលបន្ទោះដាក់សរបី ក្រែងពេលក្រក្រើទៀវដៃចាំ ៗ
ខ្លះលើកព្រះខ័នកាន់សំឡឹង សំឡក់ឈរធ្មឹងប្រឹងទន្ទ្រាំ
នេត្រប្រាលក្រហមមុខទ្រមជាំ ក្រឹតធ្មេញញញាំញាំពេកក្រៃ ៗ
ខ្លះលើកដំបងផ្គងដាក់លី គ្រក់គ្រវីខ្ចាយព្រឹក្សព្រៃ
ខ្លះឈរកាន់ព្រួងលំពែងជ័យ ខ្លះឈរក្តាប់ដៃស្កើក្អេងក្អាង ៗ
ពួកខ្លះទាញសេះដិះតម្រៀប ឈរត្រៀបទៀបផ្លូវនៅសងខាង
ខ្លះដិះដំរីបងរយោង រូបកងក្រអឹតស្អើតក្រអាញ ៗ
កកកើនច្រើនណាស់ដាសពិកព សុទ្ធសឹងតែខំពាយ៉ាំងស្កាត់ស្កាញ
ចំណាប់ស្នាដៃក្រៃជំនាញ បង្ហាញស្នួតានាក្រក្រើង ៗ
ដៃកាន់អាវុធយុទ្ធកណ្ដា រាប់ម៉ឺនកើនពាន់លាន់ទ្រហឹង
កាន់ខែលមាសពេជ្រស្រេចឈរធ្មឹង សំឡឹងទម្លុះព្តោះសត្រូវ ៗ
លុះរៀបពលផងកងពន្ទឹក ក្បួនសឹកចាក់ចែកគ្រប់ផ្នែកផ្លូវ
ក៏លើកព្យូហៈយាត្រាទៅ កម្រូវផ្លូវចរកៈប្រយុទ្ធ ៗ

កកកុញក្រញេឡើងដើងប្រទាក់ ប្រទើសគ្នាបាក់បាក់សាវុធ
ប្របៀតជ្រៀតគ្នាក្ដាឥតស្កុត ហែកទឹកសមុទ្រផុតជើបប្រាណ ។
ប្រិចប្រិចលេចចេញដូចមេក្លៀង ដែលកៀងហើរឡើងដំបូកហាន
កកកើនច្រើនជ្រួសហួសប្រមាណ ក្លាហានគ្មានឈប់គ្រប់ពួកក្រុម ។
រីឯពួកនាគកកតើងរឹទ្ធិ ដើងពិតនិត្យទៅហៅគ្នាជុំ
ប្រឹងខ្លួនពួនកាយកាយជាក្រុម ចង្កឹមធំធំជាសាវុធ ។
លុះឃើញអសុរត្បូលមកដល់ កំស្ទុះរចល់ចាប់ប្រយុទ្ធ
ពួកខ្វះទើបលើបពីសមុទ្រ នាគផុតដោយពិសពុសសាហាវ ។
អសុរបរទ័ពសង្គ្រុបរី នាគចាំងឈ្នាលញ៉ាក់ស្រវ៉ៅ
ព្រួសទាំចឹកក្រួតដាច់ខ្ទាសាវ អសុរកំកាំកាប់សាច់សង ។
រីកសន្ធឹកទឹកបែកបែង បែកចេញជាផ្សែងណាន់តឹកកង
ក្លៀងផ្គរខ្ទរពាសរំពង ពលផងមុះមុតប្រយុទ្ធចាក់ ។
បាញ់កាប់ចាប់វាយប្រញាយញឹក គគ្រឹកគគ្រែងជ្រែងទាត់ធាក់
ប៉ុន្តែគ្រប់គ្នាសូម្បីម្នាក់ មិនមានគ្រោះថ្នាក់បាក់បែកសោះ ។
គឺគ្មានអ្នកណាត្រូវស្បែកដាច់ ឬមុតធ្លុះសាច់ដាច់ស្បែកពោះ
ឬចេញលោហិតឡើងហ្មងមោះ គ្មានបន្តិចសោះគ្រប់ៗប្រាណ ។
គ្រាន់តែតក់ស្លុតនេត់ចិត្ត ចង់ដាយចង់មិតបកកហាន
ដូចជាកូនក្មេងលេងកំសាន្ត ឥតមានហ្មងមោះគ្រោះថ្នាក់ឡើយ ។

នាគរាប់កោដិលានគ្មានតក់ស្លុត ប្រយុទ្ធទប់ទល់មណ្ឌលត្រើយៈ
វាយប្រហារសត្រូវឲ្យរវើយ ឲ្យស្បើយរត់បករកកន្លែង ៗ
ឯពួកអសុរក៏រុលខ្លាំង ធ្វើយុទ្ធប្រឆាំងច្បាំងឥតក្រែង
គ្លៃផងតាំងពីរទំប្រឹងប្រែង សំដែងឫទ្ធីរៀងៗខ្លួន ៗ
តែពួកអសុរពលជោគជ័យ ច្បាំងបានថ្វីដៃយ៉ាងមាំមួន
សំពងពួកនាគឲ្យងាកខ្លួន ប្រាសព្រាត់រត់ពួនអស់ពីផ្លូវ ៗ
ហើយនាំគ្នាក្រង់កម្រង់ចំ ស្ទុះស្រឡើងក្ដុំពុំកាស្រូវ
ច្រើនពេកមេឃដីគងងឹតផ្លូវ កម្រូវកម្រង់ក្រង់ស្លូតា ៗ
លុះធ្លងពីមាគងាកទៅផុត ស្រាប់តែកើបយុទ្ធខឹងក្រុធា
ប្រុងចាត់ស្កាត់ផ្លូវទៅត្រៀបត្រា ច្រើនឥតគណនាគ្នាណែនណាន់ ៗ
ក្រញៅក្រញាំជើងក្របួច ចំពុះមុតស្រួចដូចព្រះខ័ន
ជើងតាបស្ទាបកាងភងស្រកន់ រាប់ពាន់រាប់ម៉ឺនកើនកោដិលានៈ ៗ
ហោះហើរប្រុងប្រៀបរៀបក្បួនសឹក គគ្រឹកគគ្រែងរែងក្លាហាន
លុះឃើញអសុរត្បូលដល់ឋាន គ្រប់ប្រាណចាប់ចើកឆាកប្រយុទ្ធ ៗ
ស្ទុះហោះផ្ទះចឹកចឹកស្កាត់ណាស់ ហើរប្រាសអមិត្រឥតមានស្លុត
អសុរក៏សបវាយតបគ្រុឌ ប្រយុទ្ធដណ្ដើមសម្បើមក្រៃ ៗ
ហោះផ្ទាំងគោងជើងឡើងជិះជាប់ ចុករុកចាក់កាប់បឹងឲ្យក្ស័យ
ខ្លះបាញ់ធ្នូសរខ្ទរពេញព្រៃ វិស័យដូចផុសព្យុះសង្ឃ្រាក ៗ

មហាមេឃនឹងបិទបាំងអ័ព្ទ  ដោយការចំបាប់កាប់ចាក់គ្នា

រលំព្រឹក្សព្រៃផ្ទុក្រឡា  ភស្មុជាខ្លាខ្ទើញទេពាក់ ៗ

អសុររុលបុករុកខ្មាយ  ខ្មួះខ្មុះខ្លាយភាយខ្ទាក់

ពួកគ្រុឌកប់មុឺនកើនកោដិធ្លាក់  ចាញ់បាក់បបក្ខាចអំណាចឫទ្ធិ ៗ

លុះឃើញពួកគ្រុឌរត់ដោះដៃ  ចូលព្រៃលខ្លួនពួនភ័យភីត

ស្រេចទើបព្រះបាទរេបចិត្ត  បន្ទិតម៉ែគ្រខ្លួនផ្ទួនទៅទៀត ៗ

ឲ្យរត់ទៅមុខសម្រុកចូល  ពលផងក៏មូលចូលជ្រែកជ្រៀត

តាមផ្លូវទៅក្ដិចចង្អៀត  ដល់បៀតតំបន់កុម្ភណ្ឌសឹក ៗ

ស្រាប់តែពើបពាក់អ្នកកុម្ភណ្ឌ  ច្រើនមុឺនច្រើនពាន់ឈរដូចស្ពឹក

កាន់ដាវលំពែងសំដែងឫក  ស្ទាត់ជឹកសឹកសាមសង្គ្រាមជ័យ ៗ

អសុរឃើញព្នោះក៏ពុះពារ  ឥតឲ្យយូរយោរការគៃ

សំពងកុម្ភណ្ឌជាន់បែកព្រៃ  វិស័យដូចខ្លាហាម៉ាក្ដាន់ ៗ

កុម្ភណ្ឌក៏គ្រាន់គ្មានរន្ធត់  គ្មានថយគ្មានរត់ស្ទុះសេកន់

ចាក់សបតបសាប់កាប់បន្ទាន់  សន្ធឹកខ្ញូរណន់ដូចរន្ទះ ៗ

អាខ្លះដៃដែកគ្រោបក្អែកប្រាក់  ក្បាលដូចកងចក្រវិលពង្រ៉ះ

ចេញភ្លើងឡើងក៏ស៊ើរន្ធូះ  បោលជះទៅចំក្រុមសត្រូវ ៗ

អាខ្លះបុងសក់ដូចលំពែង  គ្រវៀងកេសាការពារផ្លូវ

អាខ្លះភ្នែកលៀនមុខក្រញូវ  ង៉ាកគ្រូវៃបស្រោស្រក់ទឹក ៗ

មានគងស្បែកស្ពាន់ច្រើនពាន់នាក់ ញាំញាក់លាក់ខ្លួនតាមក្បួនសឹក
កំសួះមកកាប់សត្វសន្ធឹក គគ្រឹកគគ្រេងរង្គេងគ្នា ៗ
ឯពួកព្រះបាទរៀបចំក្តិ គ្មានកិតគិតក្រោយថយរួញរា
សំពងកុម្ភណ្ឌទន់ចេស្តា កុម្ភណ្ឌរញ្ញាររត់ពារព្រៃ ៗ
រត់ពារប្រពន្ធជាន់កូនតូច រត់ផ្លូវចូលផ្លូវនៅតែភ័យ
អសុរដេញពាន់ផ្គួលជាន់ថ្ងៃ កុម្ភណ្ឌទន់ដៃផ្ទាំស្រប៉ាប់ ៗ
អាខ្លះភ័យហួសជ្រួសធ្លាក់ជ្រោះ អាខ្លះគេចបោះផ្អោះពាបពាប
ភ័យក្រែងអសុររុលធ្វើបាប កម្ទាំងថយជាបធ្លាក់មកដី ៗ
បែកខ្ញែកប្រាសព្រាត់រត់ព្រោងព្រាត ចូលព្រៃញាតស្យាតលែងគបស្តី
រន្ធត់ស្មុគស្មាំងកាំងស្មារតី ខ្លាចបុណ្យបារមីបច្ចាមិត្រ ៗ
លុះបានឪកាសឈ្នះកុម្ភណ្ឌ អសុរច្រើនពាន់គឹបន្ទិត
បង្ខំចំពួនផ្ទួនទៅជិត គ្មានកិតគិតភ័យលៃតែស្មៀត ៗ
ឡើងស្រលើក្នុំសម្រុក ចូលបុកបើកផ្លូវតែទៅទៀត
មាតាំកាន់ណាន់ចង្អៀត ចូលជ្រៀតបៀតជល់យល់ស្លូតា ៗ
ខ្លះបោះខ្លះហើរខ្លះដើរដី ខ្លះដិះដំរីដិះសេះលា
ខ្លះវេចសំពាយស្ពាយដបស្រា ខ្លះស្រែកឡូឡាខ្ទរមណ្ឌល ៗ
កំពុងតែលើកបើកសមយុទ្ធ ចេញផុតកុម្ភណ្ឌទន់ឥទ្ធិពល
ស្រាប់តែបែរនេត្រក្លែតទៅយល់ ពួកពលយក្សយន់ពង្សក្លាហាន ៗ

ឈើកោទ់លំពែងជ្រែងដើងតាំ　　មាឌមាំសមសួនចំនួនលាន
គោដំសែនមុឺនពាន់ជាន់ទប់ប្រាណ　　ឥតមានញញើតដើតភ័យសោះ ៗ
នៅព្រៃបែរផើមម្ដងស្កាត់　　ការពារសង្កាត់ទ័ពបួននោះ
ខ្លះយាមក្ដុងដីខ្លះលៃហោះ　　ហើរឆ្លោះជ្រោះជ្រៅកំពង់ផ្លូវថ្កាន ៗ
ឈើជ្រៀតបៀតប្រកកកស្រទាប់　　សន្ទឹកសន្ទាប់កប់មិនបាន
ខ្លះមាឌធំខ្ពស់ហួសប្រមាណ　　ក្លាហានប្រឹងលោតរបូតក្បៀន ៗ
ខ្លះកងធំធាត់មាត់សំញើញ　　កញ្ចើញរីកស្បែះស្ពាយទុំទិន
ក្លាក់ដួលត្រឡប់ផ្កាប់ត្រឡិន　　សង្កិនស្រមោចហិនហោចអស់ ៗ
ខ្លះបេញចង្កូមពេមស្រម៉ូវ　　មុខខ្វិចក្រញូវមិនស្លូវស្រស់
ដេញចាប់ខ្លាញីស៊ីតាំងរស់　　ខ្លះចាប់បានពស់មកព័ទ្ធខ្លួន ៗ
ក្បាលដែកក្ដែកប្រាក់សក់ទងដែង　　ពេមជុះរែងរែងល្ហមចូលពួន
ខ្លះមានសាច់ដុំធំមាំមួន　　ក្រសួនសម្រែកស្រែកក្រអៅ ៗ
ខ្លះកាន់ធ្នូសរល្អំចំណាប់　　ខ្លះចាប់តាញព្រួញរួញខ្លួននៅ
ខ្លះកាន់ដំបងផ្គងប៉ូវថៅ　　ខ្លះបញ្ចេញក្មៅស្មុគ្រៃតយ័ន្ត ៗ
ឯពួកអសុរពលអសោច៏　　ច្រើនដូចស្រមោចគ្នានបង្អន់
ឃើញយក្សបោលចូលដូចត្រូវមន្ត　　ប្រឹងគន់កែកាប់សព្វប្រញាយ ៗ
បរសេះដំរីដីញាក់ញ័រ　　ខ្លាខ្លំគេគ្រឹកសន្ទឹកខ្លាយ
ចូលបុករុកចាក់ឥតលាក់កាយ　　ខ្លះប្រាយមិតបករកគ្នា ៗ

យក្សក៏ប្រឹងកាច់សាច់សំពង ខ្លះរងខ្លះរុលក្បុលឥតគា
ខ្លះបាញ់ផ្លូងផាំងខ្លាំងមហិមា ពសុធាតក្រើករំពើកក្រៃ ៗ
ស្មើរនឹងក្រឡាប់ផ្កាប់រលំ រលើងអស់ក៏ក្រុមព្រឹក្សព្រៃ
ទ័ពទាំងសងខាងតឹតអស់ដៃ ដណ្ដើមយកជ័យរក្សាទី ៗ
ពួកយក្សកំណាចកាចដូចភ្លើង សុទ្ធតែជាជើងពួកអាទ្រើ
ប្រឹងតឹតចំបាច់កាប់កើ ប្រឹថពីរផ្ទួលច្រួលច្របល់ ៗ
ប៉ុន្តែដោយគុណបុណ្យឥទ្ធិរិទ្ធិ នៃវេបចិត្តិអង្គិចមពល
យក្សខ្លាំងពូកែបែរស្រងល់ មិនអាចទប់ទល់តប្រឆាំង ៗ
អស់ឫទ្ធិឥតបុណ្យគុណវិបត្តិ ពលយក្សខ្លាយខ្លាត់ទទក់ម្ខាំង
អសុរបានចិត្តរឹតតែខ្លាំង យក្សតាំងកងកាយរាយមិនបែក ៗ
ដោះខ្លួនរប៉ុយដូចរុយហើរ ខ្លះទើរឈើព្រៃក៏យហួសពេក
ខ្លះក្រៀវអសុររុលចំក្អែក ខ្លះដេកស្រពាងខាងជើងភ្នំ ៗ
បក្សពួកអសុរជ្រួលជើងដេញ ដួលផ្ងើមាត់ស្ញេញឈើចង់យំ
យក្សខ្លះភ័យពេកដេកសម្ងំ ទឹកព្រួយបារម្ភក្រែងគេតាម ៗ
លុះពួកអសុរចូលតដៃ ដណ្ដើមយកជ័យពីយក្សយាម
បានហើយនាំគ្នាចេញទៅក្ងាម លើកទ័ពរុកតាមហានបពិក ៗ
ហោះហើរដើរឡើងទៅជើងភ្នំ ច្រើនក្រុមច្រើនកងធ្លុងជនបទ
ដោយបុណ្យកុសលដល់កំណត់ គ្មានហក់គ្មានអន់ទទក់ខ្លាំង ៗ

លុះឡើងដល់ភ្នំជុំពិភព(១) មកប៉ះសឹកទប់ទល់ប្រឆាំង
មួយទៀតក្លាហានមានកម្លាំង តតាំងដណ្ដើមសម្រើមក្រៃ ។
ទ័ពនោះគឺគង់ព្រះមហាកដ ទាំងប្អូនអំណាចរួមព្រួតដៃ
មានពលយោធាគ្នាច្រើនក្រៃ ពីតដៃប្រយុទ្ធបើកឈ្មុតច្បាំង ។
មហាកដទាំងប្អូនផ្ទួនតែយ៉ិត ច្បាញ់ដោយឫទ្ធិស្បូរដាំង ។
កងពលក៏បុកចូលរុកច្បាំង ប្រឆាំងរៀងខ្លួនយ៉ាងមួនមាំ ។
ប៉ុន្តែមហាកដមិនអាចទាត់ ការពារសង្កត់ទ័ពទ័ព្រុំ
ពួកពលក្រាសក្រែលដែលប្រចាំ សង្កត់ទ័ព្រុំក៏ឆ្ងាយទៀត ។
អសុរបានចិត្តតែតែដេញ ទឹកជាចំណេញពេញមានស្បៀត
លើកពលបរដល់ឋានសួគ៌ទៀត ជ្រែកជ្រៀតរែកជាន់ទេពទន់ខ្សោយ
ទេវតាចុងកាត់បិតមាត់ញក រត់ជ្រករកពួនខ្លួនឥតខ្ជោយ
អសុរដេញតាប់កាប់ពីក្រោយ ទេពតាខ្សត់ខ្សោយភ័យញ័រញាក់ ។
កើតក្ដៅក្រហាយខ្ចាយមេរោគ ពេញទាំងទេវលោកស្ទើរទីងឆ្អាក់
នៅស្រុកទេវតាកើតភ័យភ្ញាក់ គ្រោះថ្នាក់អសុររុលរុកពន ។
ឯព្រះលោកបាលទាំងប្អូនអង្គ ត្រូវបង់ជោគជ័យក្លាហាន
ទប់ទល់កម្លាំងច្បាំងពុំបាន ក៏ប្រាយប្រាសប្រាណឥតបង្អង់ ។

---

• ភ្នំដែលនៅជុំវិញភ្នំព្រះសុមេរុ មានភ្នំឈ្មោះយុគន្ធរជាដើម ដែលជាឋានរបស់ចតុលោកបាលមហារាជ ។

ទៅទូលព្រះឥន្ទពិនពិកត ជាមួយបារមីថ្ងៃចញ្ចន់
បញ្ជាក់ប្រាប់ហេតុក..ណ៍តាមគ្រន់ ទូលកឿនព្រះអង្គឲ្យប្រញាប់ ។
ព្រះឥន្ទបានស្ដាប់សរទង្ការ នៃទៅក្ដាក់ការដែលបានប្រាប់
ស្ដេចឡើងវេជយន្ត.. ប្រញាប់ បង្គាប់យោធាបញ្ជាទៅ ។
ឃើញពួកអសុររុលឥតខ្លាច ដេញពួកមហាពជទោលលំទៅ
ទ្រង់កឿនយោធាឲ្យចូលទៅ សំដៅតាំងប្រឆាំងទល់ ។
អសុរពេលនោះគ្រោះថ្នាក់ធំ ត្រូវមាំក្រំខ្នួនផ្ទួនអំពល់
ព្រះឥន្ទចាប់បោកឥតយោគយល់ ក្រហល់បកក្រោយថយប្រយុទ្ធ ។
ជ្រួលល្បិចគេចខ្លួនពួនមិនទាន់ ព្រះឥន្ទរួសរាន់កាន់អាវុធ
ចាប់ជើងគ្រវាត់ក្នុងសមុទ្រ ធ្លាក់ស្រុតផុតពីទីសួតិឋាន ។
ជ្រុះចុះរប៉ុយដូចរុយធ្លាក់ គ្មាននៅសល់ម្នាក់តាំងមុខហាន
ពួកពលអសុរអន្តរធាន អស់ពីវិមានសួតិគ្មានសល់ ។
រួចស្រេចទើបស្ដេចត្រាច់យានយាត្រ វិលចូលប្រាសាទស្អាតទំមិល
សោយសុខសម្បត្តិសម្បើមផល លែងព្រួយអំពល់ខ្វល់ហឫទ័យ ។
ឯពួកអសុរជ្រួលខ្លួនធ្លាក់ រញាញ័រញាក់ភ្ញាក់ភិតភ័យ
ដើមប្រាណបានពីផលាស័យ រត់ផាសជើងដៃចូលពិកត ។
បិទទ្វារខតយ៉ាងមាំមួន ប្រុងការពារខ្លួនតាំងថ្ងៃយប់
ទើបអស់ហឫទ័យភ័យចំប្រប់ សោយសុខក្នុងគពដូចធម្មតា ។

តាំងតែពីនោះលុះឥឡូវ　　តែដល់ផ្លូវប្រទៀនផ្កា
ចិត្តពួកអសុរកើតហានក្លា　　ឡើងកាប់ទេវតាតែកល់ផង ៗ
ប៉ុន្តែជួនកាលមិនហ៊ានរុក　　ចូលលុកដល់ឋានសួគ៌នេះផង
ព្រោះខ្លាចព្រះឥន្ទ្រចេញសំភាង　　ឲ្យហ្មង់ដូចមុនស៊ិនខ្លួនឡើយ ៗ
ឯព្រះឥន្ទ្រវិញពេញជាប្រាជ្ញ　　ដឹងថាគេខ្លាចដូច្នេះហើយ
ពេលច្បាំងមិនទៅខ្លួនឯងឡើយ　　នៅស្រណុកដើយតែគង់វាំង ៗ
ប្រើតែបុត្រម្នាក់សក្តិសមសួន　　ជាតំណាងខ្លួនទៅតតាំង
ឯពួកអសុរកុំហ៊ានច្បាំង　　សំកាំងមិតបករកឋានខ្លួន ៗ
មួយទៀតព្រះឥន្ទ្រមិត្តប្រាណ　　ឲ្យទៅទីឋានទ្វារទាំងបួន
បើពួកអសុរជ្រុលរុកគួន　　ថែខ្លួនឆាកយល់ចល់រត់ ៗ
ព្រោះខ្លាចព្រះឥន្ទ្រសក្តិនដាក់　　ចាប់ចោកចម្នាក់ម្នាក់ទឹកហ្នត់
ខ្លាចនេះខ្លាចឆាប់ជាប់ជាល្បត់　　ខ្លាចហួសកំណត់ព្រោះបារមី ៗ
នោះបើឃាំងនេះកឹអសុរ　　រុករុលចង់ពៀរជាប្រក្រតី
តែងតែនាំពលឡើងផែនដី　　ចារសិទ្ធិសេរីភាពទេវតា ៗ
ប្រសិនពួកគេមានកម្លាំង　　កំអាចតតាំងច្បាំងសេនា
នៃទាតត្រែឃយក្សក្រុមណ្ដា　　ទឹងមហាកជាចាំងបួនបាន ៗ
សម្រុកលុកដេញទេពតិករ　　រឹតរែប្រចល់ពេញសួគ៌ឋាន

ចាល់តែព្រះឥន្ទសំពន់ប្រាណ    ទើបគេវិលថ្កាខគ្មានសេសសល់ ៗ
ប្រសិនជាខ្សោយថយកម្លាំង    កងទ័ពចម្បាំងចុះទុពិល
ចូលដល់ត្រឹមនាគកំរបល់    ច្របល់គេចថយក្រោយគ្រប់គ្នា ៗ
ជួនបានឈ្នះនាគរាកចាញ់ត្រូវ    ឬចាញ់ប្រយុទ្ធកុម្ភណ្ឌ
ឬក៏ផ្កាយដល់ពលយក្ស    ឬចាញ់រាជាចាំងប្អូនអគ្គ ៗ
ក៏វិលមឹកបករកកន្ទ្វង    វង្វើងព្រាត់ប្រាសវិនាសបង់
រត់ចូលនគរគ្មានបង្អង់    តម្រង់ប្រមូលគ្នាចូលទី ៗ
បើតាមសំនួនក្បួនតម្រា    ដីកាសារត្ថទីបនី
ពោលដល់ប្រទេសទេវតាគី    ដែលជាឋានទីតាំងពីរពិត ៗ
គឺតាំងអសុរតាំងទេវតា    មានដែនសីមាជាពិសិដ្ឋ
មានភជដាទីកំពែងជិត    ទ្វារបិទឥតល្បៀតលើកពុំបាន ៗ
បើពួកអសុររុលសម្រុក    ចូលលុកបុកឆ្ពាយដល់សួគ៌ឋាន
អស់ពលទេវតាតាំងប៉ុន្មាន    ប្រាយប្រាណប្រាសចូលក្នុងនគរ ៗ
តែបិទជិតទ្វារនាកំពែង    ស្រេចហើយក៏លែងក្រែងក្តីមរណ៍
ទុកជាអសុរប្រឹងក្រដរ    ក៏ចូលនគរពុំបានឡើយ ៗ
ឯអសុរវិញក៏ជូរបោះ    ប្រសិនមានគ្រោះមកដល់ហើយ
គឺបើចម្បាំងកម្លាំងស្បើយ    ក៏មិនរកក្រើយទីពឹងខ្លួន ៗ

ប្រាសប្រាណគេប្រាលចូលវាងក្នុង កំពែងទីក្រុងដ៏មាំមួន
ទ្វារបិទជិតជាប់គ្រប់ទាំងបួន ស្រេចហើយរួចខ្លួនជាក្សេមក្សានៗ
ទោះបីទេវតាពប់កោដិច្ចាយ ក៏ទឹងខ្មាយទៅតុំបាន
ដូច្នេះនគរទាំងពីរហាន ឈ្មោះថាសុខសាន្តគ្មានចម្បាំង ៗ
គឺក្សេមទាំងប្រាណក្សាន្តទាំងកត គ្មានព្រួយពីទប់ទល់ប្រឆាំង
បើបន់ព្រះបើធ្វើចម្បាំង លុះណាតែតាំងទ័ពចេញក្រៅ ៗ
បើនៅទីក្រុងក្នុងកំពែង អស់ក៏គគិតក្រែងលែងក្តួលក្តៅ
សប្បាយកាយចិត្តឥតហ្មងសៅ សប្បាយនិត្យនៅដៅសុខសាន្តៗ
រឿងនេះស្មេះចប់បញ្ចប់ស្តី សូមលោកប្រុសស្រីមិត្តអ្នកអាន
យកជាអារម្មណ៍ផ្សំកំសាន្ត ខ្ញុំបន្ទន់ប្រាណលាសិនអើយ ។

-ចប់-